**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# រោងចក្រ ខ្វាន់ទុម អ៊ីតែរីល (ខេមបូឌា) លីមីធីត
# និង
# តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ
# រោងចក្រ ខ្វាន់ទុម អ៊ីតែរីល (ខេមបូឌា) លីមីធីត

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១៥:៣០នាទី នៅក្នុងរោងចក្រ **ខ្វាន់ទុម អ៊ីតែរីល (ខេមបូឌា) លីមីធីត** មានទីតាំងអគារF១១ ផ្លូវវែងស្រេង ភូមិទួលពង្រ សង្កាត់ចោមចៅ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះសម្ភារវត្ថុធាតុដើមសម្រាប់ផលិត(ពុំមានការបញ្ជាទិញ) ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតសរុបចំនួន**១៨៣០**នាក់ (ស្រី១៦៣៨នាក់) រយៈពេលចំនួន**៦ថ្ងៃ** គឺចាប់ពី**ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០២២ រហូតដល់ថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ ២០២២** នៅក្នុងអំឡុងពេលនៃការព្យួរការងារក្រុមហ៊ុនផ្តល់ជូនកម្មករនិយោជិតដូចខាងក្រោម៖

១. ក្រុមហ៊ុនសំរេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៨៣០នាក់ ចាប់គិតពីថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០២២ នឹងចូលធ្វើការវិញនៅថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០២២។

២. ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងផ្តល់ប្រាក់ឈ្នួលចំនួន ៥០% (ហាសិបភាគរយ) នៃប្រាក់ឈ្នួលគោលប្រចាំខែសំរាប់កម្មករនិយោជិតម្នាក់ៗ។

៣. សំរាប់អត្ថប្រយោជន៏ផ្សេងៗ ក្រុមហ៊ុននឹងរក្សាដដែលដូចខែសីហា ឆ្នាំ២០២២ លើកលែងតែប្រាក់រង្វាន់ឧបត្ថមការដេរ គឺត្រូវគិតតាមអត្រាបុងដែរកម្មករនិយោជិតម្នាក់ៗដេរបានតាមចំនួនដែលក្រុមហ៊ុនបានកំណត់។

៤. ក្រុមហ៊ុនសន្យាថាបន្ទាប់ពីត្រលប់មកចូលធ្វើការងារវិញ ក្នុងខែកញ្ញា ឆ្នាំ២០២២នេះ ក្រុមហ៊ុននឹងពុំមានការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតម្តងទៀតទេ បើទោះបីជាក្នុងខែកញ្ញា ឆ្នាំ២០២២នេះមិនមានការងារធ្វើក៏ដោយ។

៥. សំរាប់ប្រាក់ឈ្នួលប្រចាំខែ សីហា ឆ្នាំ២០២២ ក្រុមហ៊ុននឹងបើកជូនកម្មករនិយោជិតនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០២២ ដោយអ្នកស៊ីបុងគឺនៅថ្ងៃទី៣០ និង ៣១ ខែសីហា ឆ្នាំ២០២២ ក្រុមហ៊ុននឹងគិតតាមប្រាក់ខែគោល ។

៦. ក្នុងកំឡុងពេលសំរាកបុណ្យភ្ជុំបិណ្ឌនេះ ក្រុមហ៊ុនអនុញ្ញាតអោយកម្មករនិយោជិតខ្ចីលុយ ៥០ដុល្លាអាមេរិកបន្ថែមទៅលើប្រាក់ឈ្នួលលើកទី១ ក្រុមហ៊ុននឹងបើកសរុបជូនកម្មករនិយោជិតនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២។ ការកាត់លុយខ្ចី៥០ដុល្លានេះក្រុមហ៊ុននឹងកាត់ជា២លើក ដោយលើកទី១ កាត់ចំនួន៣០ដុល្លា ក្នុងប្រាក់ឈ្នួលប្រចាំខែកញ្ញា ឆ្នាំ២០២២ និងកាត់លើកទី២ ចំនួន២០ដុល្លាទៀត ក្នុងប្រាក់ឈ្នួលប្រចាំខែ តុលា ឆ្នាំ២០២២។

អង្គប្រជុំបានចប់វេលាម៉ោង១៧ និង ០០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាត និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ថ្ងៃអង្គារ ០៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ពស ២៥៦៦

ភ្នំពេញ.ថ្ងៃទី៣០សីហា ឆ្នាំ ២០២២

**នាយកក្រុមហ៊ុន**

QUANTUM APPAREL (CAMBODIA) LIMITED

Lakshman Dayasiri

**តំណាងសហជីពមានភាពជាតំណាង**
**និងតំណាងកម្មករ**